# ការសម្ភាសរបស់លោកយាយ ខឹម សុត

*កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី* *ខៈ អ្នកត្រូវបានគេសម្ភាសឈ្មោះ ខឹម សុត*

## ព័ត៌មានសង្ខេបឈ្មោះ ខឹម សុត

*លោកយាយខឹម សុត មានអាយុ៨២ ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិត្រពាំងទាប មហាឬស្សី ខេត្តកំពង់ស្ពឺ។ លោកយាយមានបងប្អូន១២នាក់ស្លាប់អស់នៅសល់សព្វថ្ងៃតែ២នាក់ ហើយលោកយាយបានរៀបការនៅអាយុ២១ឆ្នាំ មានកូនសរុប៥នាក់ តែដល់នៅក្នុងសម័យប៉ុលពត លោកយាយបានកូន២នាក់ស្លាប់ បងប្អូន និង ឪពុកក៏បានស្លាប់នៅក្នុងសម័យនោះដែរ។ ជីវិតលោកយាយខំប្រឹងដើររើសអេតចាយឡឹងគីឡូលក់ ហើយក្រោយមកដល់ឥឡូវថ្ងៃខ្លះទៅសុំទានគេ ទាំងលំបាកវេទនា ដែលមានវត្តអារាមជាទីពឹងច្រកកោន ដែលសព្វថ្ងៃលោកយាយបានមករស់នៅនឹងព្រះធម៌នៅក្នុងវត្តសង្គ្រានតាព្រហ្មស្ទឹងមានជ័យ ចំណែកបងប្អូនក៏ចាស់ៗអស់ហើយ និង កូនៗមានប្តីប្រពន្ធរស់នៅបែកគ្នាអស់ទៅ ហើយជីវៈភាពក៏មិនសូវជាធូរធារដែរ។ សម្រាប់ការផ្តែផ្តាំលោកយាយអត់មាននោះទេ ព្រោះលោកយាយមិនចង់និយាយដោយសារមានភាពខ្មាសអៀន មិនអាចនឹងប្រាប់បាន គាត់គ្រាន់តែថា បើសិនជាគេស្តាប់នោះស្តាប់ទៅចុះ មិនស្តាប់ក៏អត់ទៅ។*

កៈ ចាស!ជាដំបូង ចៅសូមជម្រាបសួរលោកយាយ។ ចៅមកពីខាងសាលាBYUនៅខាងសហរដ្ឋអាមេរិក ហើយគម្រោង១ហ្នឹងចង់ជួយចងក្រងពង្សប្រវត្តិខ្មែរ។

ខៈ ចាស!

កៈ ដែលគាត់ជីវិតបទពិសោធន៍របស់គាត់តាំងពីមុនមកចឹងណាយាយ

ខ៖ ចាស!

ក៖ ចឹងយាយអនុញ្ញាតឱ្យចៅធ្វើការសម្ភាសយាយ ដោយថតសម្លេងយាយ និង ថតរូបរបស់យាយ ទុកឱ្យកូនជំនាន់ក្រោយគេស្ដាប់ដែរឬទេយាយ?

ខ៖ ចាសៗ បានកូន!

ក៖ ចាសលោកយាយ! ចឹងមុនដំបូងនៃការសម្ភាស ថ្ងៃហ្នឹងជាថ្ងៃទី២៨ ខែ៩ ឆ្នាំ២០១៨ ហើយចៅមានឈ្មោះហេង សុជីវី គឺជាអ្នកសម្ភាស ហើយចុះលោកយាយមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំ ខឹមសុត!

ក៖ ចាស ហើយឈ្មោះហ្នឹងមានត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណអត់លោកយាយ?

ខ៖ ចាស!

ក៖ ទាំងនាមត្រកូល?

ខ៖ មានកូន!

ក៖ ទាំងនាមត្រកូលទាំងឈ្មោះរបស់លោកយាយមានឈ្មោះអ្វីដែរលោកយាយ?

ខ៖ អឹម! ខឹម សុត!

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយលោកយាយមានឈ្មោះហៅក្រៅពីហ្នឹងដែរអត់?

ខ៖ អត់ទេ!

កៈ លោកយាយឈ្មោះហ្នឹង មានអត្ថន័យយ៉ាងម៉េចដែរចំពោះលោកយាយ?

ខៈ មិនដឹងយ៉ាងម៉េច បើសិនជាយាយអត់មានដឹងដែរ ដឹងតែថាឈ្មោះចឹង។

កៈ អូ! ចាស! ចឹងលោកយាយសព្វថ្ងៃមានអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំ៨២កូន!

កៈ ចឹងលោកយាយមានបានចាំថ្ងៃខែកំណើតខ្លួនឯងកើតដែរអត់ថានៅថ្ងៃខែឆ្នាំណាដែរ?

ខៈ មានតើកូន! នៅក្នុងអត្តសញ្ញាប័ណ្ណ។

កៈ ចាស!

ខៈ ចាស!

កៈហើយលោកយាយមានស្រុកកំណើតនៅឯណាដែរ?

ខៈ ស្រុកកំណើតរបស់ខ្ញុំនៅកំពង់ស្ពឺ។

កៈ ចាស! នៅភូមិអ្វី ឃុំអ្វីដែលលោកយាយ?

ខៈ ភូមិត្រពាំងទាប មហាឫស្សី

កៈ ចាស! ហើយសព្វថ្ងៃលោកយាយមានទីលំនៅ នៅឯណាដែរ?

ខៈ នៅឯហ្នឹងពិតប្រាកដ។

កៈ នៅក្នុងវត្តសង្គ្រានតាព្រហ្មស្ទឹងមានជ័យ?

ខៈ ចាស!

កៈ ចាស!

ខ៖ មកតាំងពីរាជ គេទម្លាក់លន់ណាល់! ហើយមកខ្ញុំមកដល់ជំនាន់អាពត គេជម្លៀសទៅហើយដល់អាពតហើយមកខ្ញុំបានចូលនៅឯហ្នឹងវិញ។

ក៖ អូចាស! ហើយរយៈពេលប៉ុន្មានដែរ លោកយាយបានមកស្នាក់នៅឯទីនេះ ប្រហែលជាយូរប៉ុន្មានដែរ?

ខ៖ យូរដែរហើយកូន តាំងពីអាយុ៥០ យើងក្នុងមកដល់ពេលឥឡូវនេះយើងមាន៨២ហើយកូនគិតទៅមើល។

ក៖ ចាសលោកយាយ!

ខ៖ នៅសង្កាត់ស្ទឹងមានជ័យណា។

ក៖ ចាស! ហើយលោកយាយសព្វថ្ងៃលោកយាយមានតួនាទីធ្វើអ្វីខ្លះដែរនៅវត្តហ្នឹង?

ខ៖ អត់មានធ្វើអីនោះទេកូន រាល់ថ្ងៃ ស្មាទោស ដើររកបន្តិចបន្តួច សុំទានគេ។

ក៖ ហឺម!

ខ៖ បានៗយកមកហូប!

ក៖ ហឺ! នៅឯណាលោកយាយ! ចឹងនេះជាជីវិត តស៊ូ!

ខ៖ ចាសៗ! ជីវិតយើងនៅឃ្លានណាកូន បើសិនជាយើងមិនរកតើបានអ្វីមកហូប ហ្នឹងម៉ែប្រាប់កូនឱ្យអស់។

ក៖ ចាស! ហើយការងារដែលលោកយាយបានធ្លាប់ឆ្លងកាត់ដើម្បីចិញ្ចឹមជីវិត តើមានអ្វីខ្លះដែរ?

ខ៖ ចាស! អត់មានធ្វើអីនោះទេកូន។ រាល់តែថ្ងៃហ្នឹង រាល់តែថ្ងៃហ្នឹងមានអ្នកណាជួលទៅក៏ទៅៗ តែបើសិនជាអត់នោះក៏អត់ទៅ អត់ទៀងដែរកូនអត់មានរាល់ថ្ងៃនោះទេ ថ្ងៃណាស្រួលខ្លួនទៅៗ ដល់ពេលថ្ងៃណាអត់ក៏អត់ទៅ។ ចាស!

ក៖ ចាស!

ខ៖ ចាស!

ក៖ តែថាមុខរបរដែលយាយបានធ្លាប់ឆ្លងកាត់នោះ តើមានបានធ្លាប់ធ្វើការកន្លងមកតើមានអ្វីខ្លះដែរ?

ខ៖ ពីមុនមក កូនណា កាលពីមុនមកម្ដាយប្រាប់ ម្ដាយនៅកាយសំរាម រើសអេតចាយ។

ក៖ អូយាយអើយ!

ខ៖ ចាសខ្ញុំនៅចាក់សំរាម! នៅឯណំា នៅនោះ ចាក់សំរាមនៅឯណោះ ដល់ពេលហើយទៅ គេមកប្រតិបត្តិធម៌សី១០ ម៉ែរត់មកនៅឯហ្នឹង

ក៖ ចាស!

ខ៖ចាស! ប្រវត្តិរបស់ម៉ែមិនចង់និយាយនោះទេកូន។

ក៖ អូ! អត់អីទេ ដូចថាជីវិតមនុស្សម្នាក់ៗមានការលំបាកផ្សេងៗចឹងណា។

ខ៖ ចាសៗៗផ្សេង!

ក៖ ចឹងលោកយាយមានការតស៊ូ ចិញ្ចឹមកូនចៅ សរសើរលោកយាយមែនទែន។

ខ៖ ចាស! ចេះតែតស៊ូទៅ នៅរស់នោះ ហើយឃ្លានផង ហើយមានកូនរងារ តើបានអ្វីហូបមកហើយយើងកម្លាំងចាស់មានបានអ្វី? តើមានដៃវែង ជើងខ្លីណានឹងគេ អត់ទេកូនស្រី។

កៈ ចាស! លោកយាយ!

ខៈ ចាស! ជីវិតរបស់ខ្ញុំខុសគេ។

កៈ លោកយាយកាលពីមុនរៀនបានកម្រិតណាដែរ?

ខៈ ខ្ញុំអត់មានបានរៀននោះទេកូន។ ខ្ញុំប្រាប់កូនឯងឱ្យត្រង់អត់មានបានចេះអក្សរនោះទេ។

កៈ ចឹងចេះអានចេះអីអត់ដែរ?

ខៈ អត់នោះទេកូន។ ចាស! អត់ចេះនោះទេ។

កៈ ចុះកាលពីមុនតើឪពុកម្ដាយរបស់លោកយាយរកអ្វីដើម្បីចិញ្ចឹមជីវិតនិងគ្រួសារ?

ខៈ ម្ដាយខ្ញុំធ្វើស្រែ ហើយទៅដល់ទៅគេលើកឯលិច គេលើកឯកើតចឹងទៅ ដីស្រែនោះក៏អត់អីក៏អត់ចឹងទៅ ដល់ពេលទៅអត់មានទាន់គេ។ គេយកអស់ចឹងទៅ រត់ចូលផ្សារទៅ ប្រាប់កូនត្រង់ចឹងតែម្ដងទៅ ហ្នឹងហើយ។

កៈ ហ៊ឹមចាស! ហើយលោកយាយដូចជា កាលពីមុនហ្នឹង លោកយាយមានបានដឹងអំពីជីវិតរបស់ឪពុកម្ដាយរបស់លោកយាយកាលពីនៅក្មេងៗដែរឬទេ?

ខៈ ចាស! ខ្ញុំកាលពីពេលនៅក្មេងៗ កាលខ្លួនខ្លាំងកម្លាំងមាន ខ្ញុំចិញ្ចឹមជ្រូក ទា មាន់អីដែរចឹងណាកូន ហើយដល់ពេលចាស់ទៅយាយរត់ចូលវត្ត យាយអត់មានប៉ះពាល់អីនោះទេ ឈប់រហូត។

កៈ ចាស! ត្រូវហើយប៉ុន្តែឪពុកម្ដាយរបស់លោកយាយ?

ខៈ ឪពុកម្ដាយរបស់ខ្ញុំគាត់ធ្វើស្រែនោះទេកូន។

កៈ ចាស! គាត់មានដែរប្រាប់អំពីជីវិតរបស់គាត់ កាលពីគាត់នៅក្មេងៗឱ្យលោកយាយបានដឹងដែរឬទេ?

ខ៖ ចាសៗៗ ដឹងតើកូន គាត់ធ្វើអីនោះទេ ធ្វើតែស្រែទេ។

ក៖ អូចាស! ហើយបន្ទាប់មក តើគាត់ឈ្មោះអ្វីដែរលោកយាយ?

ខ៖ ឈ្មោះវ៉ាន់!

ក៖ ចាស!

ខ៖ កង វ៉ាន់!

ក៖ ចាស! ហើយម្ដាយ?

ខ៖ ម្ដាយឈ្មោះ យាយផាយ គាត់បានស្លាប់តាំងពីខ្ញុំមានអាយុ៨ឆ្នាំ។ គាត់បានស្លាប់ចោលទៅយូរហើយតាំងពីពេលខ្ញុំមានអាយុ៨ឆ្នាំ។ ខ្ញុំកូនពៅគេបងៗស្លាប់អស់ហើយ ហើយឪពុករបស់ខ្ញុំ ដែលនៅជំនាន់ប៉ុលពតហ្នឹង គេយកទៅវាយចោលអស់ហើយ រកអត់ឃើញនោះទេឆ្អឹង មិនដឹងនៅឯណាអីណានោះទេ។

ក៖ ហ៊ឹម!

ខ៖ អត់អាលឹង! មើលប្ដី ស្លាប់ ហើយប្អូនក៏ស្លាប់ ឪពុកក៏ស្លាប់ ស្លាប់អស់ហើយ។

ក៖ ហើយនៅជំនាន់ប៉ុលពតណុងលោកយាយ?

ខ៖ កាលជំនាន់ប៉ុលពត គេចាប់ប្ដីយកទៅវាយចោល។

ក៖ ហ៊ឹម ! ចឹងសព្វថ្ងៃលោកយាយនៅតែម្នាក់ឯងឬក៏ជាមួយនឹងកូន?

ខ៖ ចាស! នៅកូនស្រី១, ២, ៣ ប៉ុន្តែគេមានប្ដីអស់ចឹងទៅ គេនៅផ្ទះគេចឹងទៅណាកូន ហ្នឹងហើយ។

ក៖ ហ៊ឹម!

ខ៖ ជូនថ្ងៃណា គេឱ្យក៏ឱ្យទៅ ហើយបើសិនជាគេមិនឱ្យនោះក៏ហ៊ីទៅ ១ខែគេឱ្យ១០,០០០ទៅ ២០,០០០ចឹងទៅ ហើយយើងយក១ម៉ឺន ២ម៉ឺនមកនោះធ្វើអីកូនអើយ កុំនិយាយ។

ក៖ ហើយចុះបងប្អូនរបស់លោកយាយសព្វថ្ងៃមាននៅជីវិតខ្លះទេ?
ខ៖ អត់ទេ! ស្លាប់អស់ហើយ នៅតែខ្ញុំម្នាក់ឯងនោះទេ។

ក៖ ហើយកាលពីមុន កាលសម័យមុន តើលោកយាយមានកើតទាន់ជីដូនជីតាខាងឪពុកខាងម្ដាយលោកយាយដែរឬទេ?

ខ៖ ចាស! នៅទាំងអស់។

ក៖ កើតទាន់ពួកគាត់!

ខ៖ អាយុបាន២២ ម៉ែឪនៅមូលគ្នាទាំងអស់។

ក៖ ជីដូនជីតារបស់លោកយាយណា?

ខ៖ ចាស! ជីដូនជីតាខ្ញុំស្លាប់អស់ហើយ។

ក៖ តើលោកយាយមានកើតទាន់ពួកគាត់?

ខ៖ ទាន់ៗ តារបស់ខ្ញុំ។

ក៖ គាត់ឈ្មោះអ្វីខ្លះទៅជីដូនជីតារបស់លោកយាយ?

ខ៖ តាទន់!

ក៖ ហ្នឹងខាងឪពុកឬខាងម្ដាយរបស់លោកយាយ?

ខ៖ ហ្នឹងហើយម្ដាយ។

ក៖ អូ! ហើយគាត់មានប្រាប់ទូន្មានដល់លោកយាយដែរឬទេកាលណុង?

ខ៖ អត់ទេ! តែដល់ពេលក្រោយមកខ្ញុំចេះចាំ  តាទន់ យាយហ៊ីន ណុងជីដូនជីតាខ្ញុំខាងម្ដាយ ខាងឪពុកខ្ញុំមិនសូវស្គាល់នោះទេ ស្គាល់តែឪពុកខ្ញុំឈ្មោះ វ៉ាន់! កងវ៉ាន់។

ក៖ ហើយជីដូនជីតារបស់លោកយាយកាលពីមុនគាត់ប្រកបមុខរបរអ្វីដែរលោកយាយ?

ខ៖ គាត់ប្រកបមុខរបរតែធ្វើស្រែនោះទេកូន នៅស្រុកស្រែ។ ចាស!

ក៖ ហ៊ឹម! ហើយគាត់មានប្រាប់អំពីជីវិតរបស់ពួកគាត់នៅពីក្មេងៗដែរឬទេ?

ខ៖ ចាសៗ! គាត់ប្រាប់អំពីជីវិតរបស់ពួកគាតនៅពីក្មេងៗ គាត់ធ្វើតែស្រែនោះទេកូន។

ក៖ ចាស! ហើយយាយដល់ពេលចឹងកាលពីសម័យមុនមកចឹង ដូចជានៅសម័យឪពុកម្ដាយ របស់លោកយាយ គាត់មានដូចជាផ្ដែផ្ដាំដល់លោកយាយ?

ខ៖ អត់ទេកូន អត់មានផ្ដែផ្ដាំដល់កូនចៅណានោះទេ អាពត យកទៅវាយចោលអស់ហើយ ទាំងអស់ អស់១២នាក់នៅក្នុងគ្រួសាររបស់ខ្ញុំ។

ក៖ កាលណុងតើគេជម្លៀសលោកយាយ និង ក្រុមគ្រួសារទៅឯណាដែរ? នៅខេត្ត ភូមិ ឃុំអ្វី ដែរ?

ខ៖ ឃុំហេស?

ក៖ ចាស!

ខ៖ ឃុំមហាឬស្សី!

ក៖ អូ! គេជម្លៀសលោកយាយទៅណុងហ្ន៎?

ខ៖ ចាស!

ក៖ ហើយគេប្រើលោកយាយធ្វើអ្វីខ្លះទៅពេលណុង?

ខ៖ កាលជំនាន់ប៉ុលពតគេឱ្យឃ្វាលក្របី គ្នា៣នាក់ ក្របី១០០ ហ្នឹងជំនាន់ប៉ុលពត។

ក៖ ហើយបន្ទាប់មក គេមានធ្វើបាបលោកយាយដែរឬទេ?

ខ៖ អត់នោះទេកូន។ គេអត់មានធ្វើបាបធ្វើអីនោះទេ ដល់ពេលថ្ងៃ១ក្របីវាទៅស៊ីស្រូវគេ ឃុំគេផ្សេងណា ហើយដល់នេះគេលើក គេលើកមកដល់ភូមិខ្ញុំហ្នឹង។ គេលើក គេថាខ្ញុំស្មានតែទោស សូមអភ័យទោសឱ្យខ្ញុំផង ព្រោះអីក្របី វាត្រូវទឹកភ្លៀង វាបោលហើយណា ដល់ចឹងវាបោលទៅស៊ីស្រូវគេ ដល់ចឹងគេក៏អត់មាត់អត់អីចឹងទៅ។

ក៖ ចាស!

ខ៖ (លោកយាយប្រាប់គេនៅជិតនោះទេ៖ គេសម្លាសខ្ញុំកាលនៅជំនាន់ប៉ុលពត។ ចាស!)

ក៖ យ៉ាងម៉េចទៅលោកយាយ?

ខ៖ ខ្ញុំក៏ឆ្លើយទៅតាមដំណើរចឹងទៅ ដល់ពេលថ្ងៃក្រោយមកគេឱ្យទៅទៀតចឹងទៅ គេឱ្យទៅឃ្វាលទៀតចឹងទៅ។

ក៖ ហ៊ឺម!

ខ៖ ហើយមិនដែលបានស្រួលនឹងគេនោះទេកូនអើយ ស៊ីតែព្រលិត ស៊ីតែត្រកួន អង្ករមួយគ្រាប់ៗស៊ីតែដំឡូងមី។

ក៖ ចាស!

ខ៖ បានមកបែកហ្នឹងពី៧៩ ហើយបានមកដល់ឥឡូវមិនដែលថាបាន១កំណាត់ហូបនឹងគេនោះទេ។ គេមើលអត់ឃើញ ថាយើងមាន ខ្ញុំមិនដែលបាន បាននឹងគេនោះទេ។ គេបានថាគ្នាគេមានបានចឹងទៅហើយដល់ពេលឯងអត់ចឹងទៅ។

ក៖ ហើយលោកយាយនៅពេលណុងដូចជា...

ខ៖ ហើយចេះតែរស់ទៅកូន មិនដឹងត្រូវធ្វើយ៉ាងម៉េច ចេះតែរកនេះនោះៗចឹងទៅ បានហូបទៅ ឱ្យកូនហូបទៅ ទាល់តែសព្វថ្ងៃចឹងទៅណាកូន។

ក៖ ចាស! ហើយចឹងពេលណុងលោកយាយដូចជានៅកាលសម័យជំនាន់ប៉ុលពតណុង ធ្លាប់ឃើញមនុស្សគេយកទៅស្លាប់ចោលនៅនឹងភ្នែក?

ខ៖ ហ៊ឹម! ចេះតែឃើញហើយតែអ្នកណាហ៊ាននិយាយ បើសិនជាប្ដីគេយកទៅវាយចោលនៅនឹងមុខយើងផង តើអ្នកណាទៅហ៊ានមាត់ គេបាត់មុខជិតឈឹងគេយកទៅព្រៃទៅ គេយកទៅវាយទៅ មិនដឹងត្រូវធ្វើយ៉ាងម៉េច។ តើអ្នកណាទៅហ៊ានធ្វើអ្វីនឹងគេ យើងស្រីទៅតតាំងអ្វីនឹងគេស្រាច់តែគេ។

ក៖ ហឹម ចឹងអឺ ស្វាមីលោកយាយប៉ុលពតយកទៅនឹងមុខលោកយាយ?

ខ៖ ចាស!

ក៖ ចាសសោកស្ដាយណាស់លោកយាយ។

ខ៖ ខ្ញុំឃើញនឹងភ្នែករបស់ខ្ញុំណា មិនបាច់អ្នកណាប្រាប់អីនោះទេ។ ចឹងដូចថាវាលចឹង ដូចជាត្រពាំងទឹកចឹងដេកនៅត្រពាំងទឹក ហើយដេកនៅម្លប់ ដល់ពេលគេលែងអាក្របីហ្នឹងទៅ ក្របីហ្នឹងដេកនៅក្នុងទឹកចឹងទៅ ឱ្យប្ដីខ្ញុំអង្គុយ ហើយខ្ញុំមើលពីលើផ្ទះទៅឃើញចុះផ្ទះវាល មើលឃើញ ហើយគេបិទហើយ ដល់ស្អែកឡើងល្ងាចឡើងគេយកគាត់ទៅវាយចោលនៅឯជើង។

ក៖ ហ៊ឹមលោកយាយអើយ ហើយពេលសម័យជំនាន់នៅ។ កាលណុងតើគេឱ្យលោកយាយដេកបានប៉ុន្មានម៉ោងដែរ?

ខ៖ ហូស! មិនបាននិយាយនោះទេរឿងដេកហ្នឹង ព្រឹកឡើងយកក្របីទៅ ម៉ោង៧ចេញទៅរហូតទាល់ម៉ោង៥បាន ដេញក្របីចូលក្រោល។

កៈ ហើយនៅពេលណុង តើលោកយាយមានបានចង់ចាំទិដ្ឋភាពអ្វីខ្លះដែរ កាលនៅសម័យណុង?

ខៈ ចាស! ខ្លាចគេ កូនៗយំ ព្រោះផ្គរលាន់ ហើយប្រាប់វាថាកុំយំ។ បើសិនជាយំទៅគេយកទៅវាយចោលអស់មួយពូជទៀតឥឡូវហើយ ប្រាប់កូន កូននោះក៏អត់ហ៊ានបែកគ្នា កូន១នាក់នៅកុមារហើយមីនេះរែកអាចម៍គោ មីហ្នឹងរែកអាចម៍គោ ហើយរើសតែបាយស៊ីនោះទេ រើសបាយតែ១គ្រាប់២គ្រាប់ ហើយខ្ញុំទៅឃ្វាវក្របីនុង សុំបាយក្ដាំងគេមក យកមកទុកឱ្យកូននៅផ្ទះចឹងទៅ ហើយដល់ពេលខ្ញុំមកវិញចឹងទៅ ហើយឱ្យកូនហូបទៅនៅរោងគេចឹងទៅ ហូបកើតក៏កើតទៅ។ បើសិនជាមិនកើតក៏ចេះតែទៅទៀតទៅ កម្សត់ណាស់កូនអើយ ប្រវត្តិនោះវាជូរចត់ណាស់ មិនដឹងត្រូវធ្វើយ៉ាងម៉េចនោះទេកូន។ សព្វថ្ងៃបានថាម៉ែមិនចង់នេះនោះទេកូន។

កៈ ហើយពេលណុងលោកយាយដូចជា ចងចាំទិដ្ឋភាពអ្វីខ្លាំងជាងគេនៅប៉ុលពតណុង?

ខៈ កូនៗគេឃើញនេះឃើញនោះ គេធ្វើសំណង់ធ្វើអីចឹងទៅ ដល់ពេលបានទៅយកមកផ្សំគ្នាហូបទៅ ហ្នឹងបានបន្តិចមកហើយនោះបានបន្តិចទៅ។

កៈ ហ៊ឹម!

ខៈ ចាស!

កៈ យាយឆ្លងកាត់ជំនាន់អ្វីខ្លះ?

ខៈ ជំនាន់ឥស្សរទំពាំស្ដៅ។

កៈ ចឹងកាលណុងតើយ៉ាងម៉េចដែរទៅកាលនៅជំនាន់ឥស្សរនោះលោកយាយ?

ខៈ ហ៊ឹម កូនអើយ! អារឿងជំនាន់ឥស្សរកាលពីដំបូងថាដូចជំនាន់ប៉ុលពតម៉េចគឺចឹង។

កៈ ចាស! ចឹងកាលណុងជីវិតរបស់លោកយាយយ៉ាងណាដែរ? នៅសម័យជំនាន់ណុង?

ខ៖ ចាសៗ អត់អីនោះទេកូន។

ក៖ អូ!

ខ៖ ថាប្រវត្តិរបស់យាយនេះវាជូរចត់ណាស់ កូនអើយ មិនសមហ្នឹងរស់នោះទេ។

ក៖ ហ៊ឺម!

ខ៖ បងៗគេស្លាប់អស់ហើយ នៅតែម្នាក់ឯងនោះទេ សព្វថ្ងៃនេះ រាល់តែថ្ងៃនេះ ក៏មិនបានដឹងថានៅថ្ងៃណាស្លាប់ដែរកូន អត់ទៀងនោះទេ។

ក៖ ហ៊ឺម!

ខ៖ ចាស!

ក៖ ហើយយាយមានបំណងប្រាថ្នាអ្វីដែរ?

ខ៖ អត់មានប្រាថ្នាអ្វីនោះទេកូន មកដល់រាល់ថ្ងៃហ្នឹង ប្រាថ្នាយាយមានតែប្រាថ្នាព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹង ជាទីរលឹក ស្មើដល់ជីវិតរបស់ខ្ញុំ ព្រះសាមាសាមពុទ្ធ អង្គដោយគោរព ខ្ញុំគោរពតែព្រះពុទ្ធព្រះធម៌ព្រះសង្ឃនោះទេកូន។ ថ្ងៃសីលឡើងខ្ញុំទៅសុំសីលទៅ ដល់ពេលថ្ងៃសីលខ្ញុំទៅសុំសីលទៅ ១ថ្ងៃ៤ដងទៅ ធ្វើបាយសម្លទៅ ទៅសុំសីលទៅ។

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយជីវិតរបស់លោកយាយ មានរឿងអ្វីដែលធ្វើឱ្យលោកយាយសប្បាយចិត្តទេ?

ខ៖ អត់ទេ! អត់មានរឿងអ្វីដែលធ្វើឱ្យសប្បាយនោះទេកូន! យើងក្រ តើបានអ្វីសប្បាយហ្នឹងគេកូន មានលុយមានអីឯណាអត់។

កៈ ហ៊ឹម! ហើយយាយចឹង តើយាយចូលចិត្តស្តាប់បទចម្រៀងដែរឬទេយាយ?

ខៈ អត់ទេ! ម្តាយអត់ស្តាប់នោះទេកូន។

កៈ ហ៊ឹម!

ខៈ និយាយទៅស្តាប់តែព្រះធម៌ទៅ ហើយនិង លោកទេសទៅ លោកទេសហើយនៅពេលយប់ឡើង បើកស្តាប់ទៅ ដល់ពេលយប់ឡើងបើស្តាប់ទៅ ឱ! ជីវិតខ្ញុំអើយរស់នៅពឹងតែព្រះធម៌។

កៈ ចាស! ហើយចុះកាលពីនៅកុមារភាព តើលោកយាយចូលចិត្តលេងល្បែងអ្វីដែរ?

ខៈ អត់នោះទេ! កាលពីដើម មើលតែគោនិងក្របី នៅពីក្មេងអត់មានដែលហ៊ានដើរទៅណាអីនឹងគេនោះទេ អត់រលីង។

កៈ ហ៊ឹម!

ខៈ អត់ចុះបងប្អូនច្រើន បងប្អូនដល់ទៅ១២នាក់ បងប្អូន ហើយមកដល់ពេលឥឡូវងាប់អស់ហើយ នៅសល់តែ២។

កៈ ហាក់! ចឹងគាត់នៅរស់ដែរ?

ខៈ ចាស!

កៈ គាត់នៅឯណាដែរបងប្អូនយាយ?

ខៈ នៅឯកំពត!

កៈ ហើយគាត់មកលេងយាយដែរអត់ចឹង?

ខៈ ជួនណាមក ហើយជួនណាអត់។

កៈ តើគាត់ឈ្មោះអ្វីខ្លះបងប្អូនយាយដែលនៅរស់?

ខៈ នៅរស់ហ្នឹងហោស?

កៈ ចាស!

ខៈ នែក វ៉ាន់អឿន មីអឿននេះបង ហើយគឿននេះប្អូន។

កៈ ចាស!

ខៈ ចាស! នៅតែប៉ុណ្ណឹងនោះទេ។

កៈ ហើយយាយកូនទីប៉ុន្មាននៃគ្រួសារដែរ?

ខៈ ខ្ញុំហោស? កូនទី១។

កៈ អូ បងគេទៀត?

ខៈ ចាស! ខ្ញុំអត់បងគេនោះទេ កូនពៅគេទេ។

កៈ កូនពៅវិញ?

ខៈ ចាសៗ! ប្អូនពៅនោះទេបងៗស្លាប់អស់ហើយ។

កៈ ចុះបងប្អូនយាយ២នាក់ដែលនៅរស់ហ្នឹងត្រូវជាបងយាយឬក៏ប្អូនយាយ?

ខៈ អាហ្នឹងប្អូនខ្ញុំ។ ចាសៗ!

កៈ អូ!

ខៈ ប្អូនទេនៅ២នាក់ហ្នឹងប្អូនទេ ហ្នឹងឪពុកជាមួយនឹងគ្នា ឪពុកជាមួយគ្នាម្តាយរាល់ខ្លួនណា ចាស! ប៉ុណ្ណឹងនោះទេកូន។

កៈ ចាសយាយ!

ខៈចាស!

កៈ ហើយចឹងកាលពីមុនមកយាយដូចជាធ្លាប់មានការលំបាកអ្វីខ្លះដែរបានធ្វើឱ្យជីវិតយាយចង់ចាំអត់មានភ្លេចសោះ?

ខៈ ហ៊ឹមកូនអើយ! ១ខែ ៣០ឆ្នាំមិនដែលបានសប្បាយអីហ្នឹងគេនោះទេ គ្រាន់តែថារាល់ខែរាល់ឆ្នាំ។

កៈ ហ៊ឹមចាស!

ខៈ ចាស! នេះកូនពៅខ្ញុំ។

កៈ ចាសយាយ!

ខៈ នេះបង វានៅជាប់តែខ្ញុំតែមួយ។ ចាស!

កៈ សព្វថ្ងៃកូនចៅយាយ នៅជុំគ្នាយាយ?

ខៈ អត់ទេកូននៅនោះមួយៗ ចឹងទៅវាមានប្ដីមានអីចឹងទៅ។

កៈ អូ!

ខៈ ចាស!

កៈ ចាស! ហើយយាយតែងតែដូចជាចង់ឱ្យពួកគាត់យ៉ាងណាដែរ នៅក្នុងគំនិតនៅក្នុងចិត្តយាយណា តើលោកយាយចង់ឱ្យកូនចៅរបស់យាយយ៉ាងម៉េចដែរ?

ខៈ វាមានទៅទាស់អី អត់អីនោះទេកូន កូនចៅនោះ វាធម្មតា។ ចាស!

កៈ តែថាជំបូន្មានតើយាយមានចង់ទូន្មានដល់គាត់យ៉ាងម៉េចដែរជាពាក្យផ្ដែផ្ដាំណា?

ខ៖ អត់ទេ! អត់មានផ្តែផ្តាំអីនោះទេកូន។

ក៖ អឺ! យាយអត់មានពាក្យអ្វីដើម្បីនិយាយជាមួយនឹងកូនចៅយាយទេចឹង?

ខ៖ កូនចៅ យាយនិយាយធម្មតាចឹងទៅ។

ក៖ ហ៊ឹមចាស! ហើយអឺសម្រាប់ជីវិតរបស់យាយពេលដែលជួបការលំបាក តើយាយតែងតែធ្វើអ្វីដើម្បីនឹងលួងចិត្តខ្លួនឯងអីណា?

ខ៖ លួងចិត្តខ្លួនឯងគឺថាប្រឹងរកស៊ីដោយខ្លួនឯងទៅ ថ្ងៃណាថ្ងៃហ្នឹងទៅ។

ក៖ ហ៊ឹម!

ខ៖ ចាស! មានតែប៉ុណ្ណឹង ចុះបើសិនជាមេឃវាមិនរលំ ភ្នំវាបានផ្អែកទៅហើយចឹង តើត្រូវទៅពឹងនៅឯណាពឹងប្តី ហើយចុះអត់មានប្តី នោះគឺយើងត្រូវរំពឹងដោយខ្លួនយើងហើយណាកូនមិនចឹងហោសកូន? តែថារកបានហូបគឺដោយខ្លួនយើង ហើយរកមិនបានហូបតែខ្លួនយើង រកមកបានឱ្យកូនមក យាយហូបចឹងទៅ ហើយចៅហូបចឹងទៅណា មិនចឹងហោសកូន? កូនឯងក៏ចឹងមិនចឹងហោស? ចាស! ខ្ញុំមានតែពាក្យប៉ុណ្ណឹងនោះទេកូនស្រី។

ក៖ ចាសយាយ!

ខ៖ ចាស!

ក៖ ហើយសម្រាប់ដូចជាជីវិតរបស់យាយដែលមានការលំបាកអីចឹងណា ចឹងយាយមានធ្វើអ្វីដើម្បីបំបាត់ទុក្ខណា?

ខ៖ ទេ ធម្មតាទេកូន។

ក៖ អូ! យាយចូលចិត្តពិសារមុខម្ហូបអ្វីដែរ?

ខ៖ រាល់ថ្ងៃហោស?

ក៖ ចាស!

ខ៖ ត្រី!

ក៖ ចឹងចូលចិត្តត្រី?

ខ៖ ចាស!

ក៖ ឱ្យតែម្ហូបត្រីចូលចិត្តទាំងអស់តែម្តងយាយហោស?

ខ៖ ចាស!

ក៖ ហើយកាលពីមុនមក យាយចូលចិត្តពិសារមុខម្ហូបត្រីដែរ?

ខ៖ អូ! កូនអើយ! ប្រហុកក៏មាន អំបិលក៏មាន កាលនៅស្រែ ជនបទ យើងរកអ្វីមិនបានប្រហុកទៅហូបទៅ មួយពេលៗរួចទៅ។ ចាស! អត់ចេះរើសនោះទេ នាំកូននាំចៅហូបទៅ ហើយដល់ពេលថ្ងៃស្អែកឡើងរកទៀតទៅបានមកហូបទៀតទៅ។

ក៖ ចាស!

ខ៖ ចាស! មានតែប៉ុណ្ណឹងនោះទេកូន។

ក៖ ហើយយាយរៀបការកាលពីជំនាន់មុនជាមួយនឹងលោកតា តើយាយស្រឡាញ់គ្នាឬក៏ឪពុកម្តាយទុកដាក់ឱ្យ?

ខ៖ មានអីគាត់រកបានមក នៅលើខ្ញុំទៅ។ គាត់រកបានមកនៅលើខ្ញុំទៅខ្ញុំចាក់ចែងម្ហូបម្ហាអីទុកឱ្យគាត់ទៅ ទុកឱ្យគាត់ហូបទៅ គ្រាន់បានចិញ្ចឹមកូនបានរស់ទាល់មកដល់ពេលឥឡូវនេះណាកូន។ បើសិនជាមិនចឹងនោះទេ មិនដឹងថាត្រូវទៅរកនៅច្រកណានោះទេ កូនអើយ។

ក៖ តើលោកតាមាននឈ្មោះអ្វីដែរ?

ខ៖ ពីណា?

ក៖ លោកតាស្វាមីយាយមានឈ្មោះអ្វីដែរ?

ខ៖ ហៃមចារិន!

ក៖ គាត់រាល់ថ្ងៃមានជីវិតរស់ដែរឬទេយាយ?

ខ៖ចាស!

ក៖ តើគាត់រស់នៅទាល់តែសព្វថ្ងៃនេះតើហេសយាយ?

ខ៖ ចាស! គាត់កាលពីជំនាន់ប៉ុលពត គេយកទៅវាយចោល។

ក៖ អូ សុំទោសយាយ។ កាលពីមុនហ្នឹងលោកយាយស្រឡាញ់គ្នាឬក៏ឪពុកម្តាយជាអ្នករៀបចំទុកដាក់ឱ្យ?

ខ៖ចាស!

ក៖ ចឹងឪពុកម្តាយជាអ្នកទុកដាក់ឱ្យហ្ន៎?

ខ៖ចាស!

ក៖ អូ! ហើយកាលពីសម័យមុនហ្នឹង លោកយាយបានរៀបការតាមប្រពៃណី?

ខ៖ ចាសៗ! ត្រឹមត្រូវហើយ។

ក៖ លោកយាយអាចប្រាប់បានដែរឬទេថា ពេលមុនហ្នឹង លោកយាយជួបជាមួយនឹងលោកតានៅពេលណាដែរ?

ខ៖ ចាស? លោកតាដែលខ្ញុំបានជួបជាមួយនឹងគ្រួសារខ្ញុំហ្នឹង ពេលខ្ញុំដែល២១ អាយុ២១។

កៈ ចាស! បានរៀបការហ្នឹង?

ខៈ ចាស!

កៈ ហើយពេលយាយរៀបការហ្នឹង ពេលចូលថ្ងៃការហ្នឹងបានឃើញគាត់?

ខៈ ចាស!

កៈ អត់ដែរស្គាល់លោកតាពីមុនមកទេ?

ខៈ អត់! អត់មានដែលស្គាល់នោះផង!

កៈ ហ៊ឹស! ចាស! ដល់ពេលកាលណុងតើមុខរបររបស់គាត់ធ្វើអ្វីដែរ?

ខៈ របររបស់គាត់ធាក់ស៊ីក្លូ កម្មករ ធាក់ស៊ីខ្លូ។

កៈ ហ៊ឹម!

ខៈ ហ្នឹងគាត់បានចិញ្ចឹមជីវិតរបស់គាត់រស់។

កៈ ចាស! ដល់ពេលទៅ គាត់និងលោកយាយបានចាប់ដៃគ្នាបានរយៈពេលប៉ុន្មានដែរ?

ខៈ យី! យូរដែរណុង ចាំមើល តាំងពីម្ភៃប៉ុន្មាននោះទេ ដូចជាម្ភៃបួនអីទេ។

កៈ ចឹងយាយបានកូនប៉ុន្មាននាក់ដែរយាយ?

ខៈ ខ្ញុំ៥!

កៈ អូ!

ខៈ ស្លាប់នៅជំនាន់ប៉ុលពតនុងគឺប្ដីខ្ញុំមួយ ឪពុកខ្ញុំមួយ និងកូនខ្ញុំ២ នៅអាទីមួយ ចឹងខ្ញុំបានកូន ៤។

កៈ ចាស!

ខៈបានកូនទី៥ បានមីពៅនេះ១ កើតនៅជំនាន់ប៉ុលពត។

កៈ ចុះកូនលោកយាយសព្វថ្ងៃគាត់នៅឯណាដែរ ហើយគាត់មានមុខរបរអ្វីដែរលោកយាយ?

ខៈ អឺ! មុខរបរ គេនៅឯស្រែឯនោះ។

កៈ គាត់រៀនសូត្រដល់កម្រិតណាដែរ?

ខៈ ចាស! អត់ដឹងអី។

កៈ ចាស!

ខៈ ហេស! ខ្ញុំឱ្យកូនរៀនសូត្រ មិនបានជិតដល់អីប៉ុន្មាននោះទេ ព្រោះអីយើងអត់ដឹងស្រាប់ហើយ។

កៈ ហ៊ឹម!

ខៈ រៀនទើបតែបានត្រឹមថ្នាក់ទី៣ ទី៤ហ្នឹង តែប៉ុណ្ណឹងចាស ហើយបានឈប់ទៅ ជួយរកម៉ែទៅ ឈប់ទៅ ទាំងអស់គ្នាទៅ អ្នកនេះរកនេះ អ្នកនោះរកនោះចឹងទៅបាន ហូបទាំងអស់គ្នាចឹងទៅ

កៈ អូ១

ខៈចាស!

កៈ ហើយចុះយាយយល់យ៉ាងណាដែរចំពោះការសិក្សា?

ខៈ អត់មានស្អីនោះទេកូន ជាធម្មតា។

កៈ ចាស! ចឹងចុងក្រោយតើយាយមានពាក្យពេចន៍អ្វីដើម្បីធ្វើការផ្ដែផ្ដាំកូនចៅជំនាន់ក្រោយដែលគេបានស្ដាប់សម្លេងយាយណា?

ខ៖ ចាស! ចេះតែណែនាំកូនទៅ បើសិនជាគេស្តាប់ក៏ស្តាប់ទៅ បើសិនជាគេមិនស្តាប់ក៏មិនបានដឹងថាត្រូវធ្វើយ៉ាងម៉េចគេដែរនៅតែលើម៉ែ។

ក៖ ចឹងដូចថានៅក្នុងជីវិតរបស់លោកយាយមានបទពិសោធន៍ ច្រើនតាំងពីមុនមកចឹងណា

ខ៖ ចាស!ៗ

ក៖ ចឹងយាយមានដូចថាដំបូន្មាន ឬក៏មានរឿងអ្វីដែលជាមេរៀនជីវិតដើម្បីទុកអោយកូនចៅជំនាន់ក្រោយស្តាប់?

ខ៖ គឺស្រាច់តែគេ ព្រោះគេរាល់ខ្លួន មិននៅជាប់ជាមួយនិងខ្ញុំឯណា ចឹងដូចថាកូនឯងហ្នឹងខ្ញុំចឹងណា កូនឯងផ្សេងទៅ ហើយខ្ញុំផ្សេងទៅ! ហើយមិនដឹងចិត្តគេយ៉ាងរបៀបយ៉ាងម៉េចមើលចិត្តអត់ឃើញ។

ក៖ ត្រូវហើយយាយ។

ខ៖ ចាសៗ!

ក៖ ប៉ុន្តែយាយមានពាក្យពេចន៍អ្វីដើម្បីផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយណា ដូចថាដំបូន្មានយាយប្រាប់គេណា?

ខ៖ ប្រដៅទូន្មានកូនថា អីធ្វើការរកស៊ីកុំឱ្យ ក្រលំបាករហេមរហាមណាកូន ខំប្រឹងរកស៊ីណា។

ក៖ ហ៊ឹម!

ខ៖ ចាស! ដាស់តឿនគេតែប៉ុណ្ណឹងនោះទេ។

ក៖ ចាស!

ខ៖ ចឹងលោកយាយបើសិនជាខាងសាលាគេចង់ដាក់សម្លេងរបស់លោកយាយនៅក្នុងវេបសាយមួយនេះ ដើម្បីយកទុកឱ្យកូនចៅជំនាន់ក្រោយគេបានស្តាប់ណា ក្នុងវេបសាយ www.cambodiaoralhistory.byu.eduណាលោកយាយ។

ខ៖ អាហ្នឹងស្រាច់តែគេ បើសិនជាគេស្តាប់ក៏ស្តាប់បើសិនជាគេមិនស្តាប់ក៏អត់។

ក៖ ចាស!

ខ៖ ចាស!